**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

លេខ ១៩៩១ សហវ.ប្រក

រាជធានីភ្នំពេញ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥

# ប្រកាស
## ស្តីពី
## ការប្រគល់សិទ្ធិជូនប្រធានមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី ខេត្ត និងប្រធានរតនាគាររាជធានី ខេត្ត

## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ន.ស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញប្រកាសលេខ ១៨៩០ សហវ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥ ស្តីពីនីតិវិធីនៃការគ្រប់គ្រងរដ្ឋទេយ្យចំណូលសម្រាប់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## សម្រេច

**ប្រការ១.-**

ប្រគល់សិទ្ធិជូនប្រធានមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី ខេត្តនិងប្រធានរតនាគាររាជធានី ខេត្តចំពោះការបង្កើតរដ្ឋទេយ្យចំណូល និងការតែងតាំងរដ្ឋទេយ្យករចំណូលនៅតាមមន្ទីរជំនាញរាជធានី ខេត្ត និងអង្គភាពថវិកានៅថ្នាក់រាជធានី ខេត្ត ដូចខាងក្រោម÷



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St,92, Sangkat Wat Phnom , khan Daun Penh, Phnom Penh, CAMBODIA.
ទូរសព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

១). ប្រធានមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី ខេត្ត ពិនិត្យ និងចុះហត្ថលេខា រួមគ្នាជាមួយប្រធានមន្ទីរជំនាញរាជធានី ខេត្ត ឬ ប្រធានអង្គភាពថវិកានៅថ្នាក់រាជធានី ខេត្ត លើសេចក្តីសម្រេចស្តីពីការបង្កើតរជ្ជទេយ្យចំណូលរបស់មន្ទីរជំនាញរាជធានី ខេត្ត ឬ អង្គភាពថវិកានៅថ្នាក់រាជធានី ខេត្ត (ដូចមានកំណត់ជាឧបសម្ព័ន្ធទី១.១ នៃប្រកាសនេះ)។ រីឯប្រធានរតនាគាររាជធានី ខេត្ត ត្រូវពិនិត្យនិងផ្តល់យោបល់លើសំណើសុំបង្កើតរជ្ជទេយ្យចំណូលរបស់មន្ទីរជំនាញរាជធានី ខេត្ត ឬ អង្គភាពថវិកានៅថ្នាក់រាជធានី ខេត្ត (ដូចមានកំណត់ជាឧបសម្ព័ន្ធទី១.២នៃប្រកាសនេះ)។

២). ប្រធានមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី ខេត្ត ពិនិត្យ និងចុះហត្ថលេខា លើសេចក្តីសម្រេចស្តីពីការតែងតាំងរជ្ជទេយ្យករចំណូលរបស់មន្ទីរជំនាញរាជធានី ខេត្ត ឬ អង្គភាពថវិកានៅថ្នាក់រាជធានី ខេត្ត (ដូចមានកំណត់ជាឧបសម្ព័ន្ធទី២.១នៃប្រកាសនេះ)។ រីឯប្រធានរតនាគាររាជធានី ខេត្ត ត្រូវពិនិត្យនិងផ្តល់យោបល់លើសំណើសុំតែងតាំងរជ្ជទេយ្យករចំណូលរបស់មន្ទីរជំនាញរាជធានី ខេត្ត ឬ អង្គភាពថវិកានៅថ្នាក់រាជធានី ខេត្ត (ដូចមានកំណត់ជាឧបសម្ព័ន្ធទី២.២នៃប្រកាសនេះ)។

**ប្រការ២.-**

រជ្ជទេយ្យករចំណូលរបស់មន្ទីរជំនាញរាជធានី ខេត្ត និងអង្គភាពថវិកានៅថ្នាក់រាជធានី ខេត្ត ត្រូវបំពេញបែបបទស្នើសុំបើកគណនី នៅរតនាគាររាជធានី ខេត្ត។

រជ្ជទេយ្យករចំណូលរបស់មន្ទីរជំនាញរាជធានី ខេត្ត និងអង្គភាពថវិកានៅថ្នាក់រាជធានី ខេត្ត ត្រូវប្រគល់សេចក្តីសម្រេចស្តីពីការតែងតាំងរជ្ជទេយ្យករចំណូល និងសេចក្តីសម្រេចស្តីពីការបង្កើតរជ្ជទេយ្យចំណូល ចំនួន ១ច្បាប់ ជូនរតនាគាររាជធានី ខេត្ត និង ១ច្បាប់ ជូនមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី ខេត្ត។

**ប្រការ៣.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៤.-**

នាយកខុទ្ទកាល័យ អគ្គលេខាធិការ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក អគ្គនាយកនៃអគ្គនាយកដ្ឋានរតនាគារជាតិ អគ្គាធិការ ប្រធានមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី ខេត្ត និងប្រធានគ្រប់អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

**រដ្ឋមន្ត្រី**
**ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន**

**<u>កន្លែងទទួល៖</u>**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- សាលារាជធានី ខេត្ត
- គ្រប់មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងគ្រប់រតនាគាររាជធានី ខេត្ត
- ដូចប្រការ ៤
- ឯកសារ-កាលប្បវត្តិ

**ឧបសម្ព័ន្ធទី១.១**

គំរូសេចក្តីសម្រេចស្តីពីការបង្កើតរជ្ជទេយ្យចំណូលនៅមន្ទីជំនាញរាជធានី ខេត្ត ឬ អង្គភាពថវិកានៅថ្នាក់រាជធានី ខេត្ត ដែលបានអនុវត្តរជ្ជទេយ្យចំណូល

# សេចក្តីសម្រេច

# ស្តីពី

# ការបង្កើតរជ្ជទេយ្យចំណូល

**នៅមន្ទីរ......... ឬ នៅអង្គភាពថវិកា..........រាជធានី/ខេត្ត...................................**

**ប្រធានមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី/ខេត្ត......　　ប្រធានមន្ទីរ....ឬ ប្រធានអង្គភាពថវិកា....រាជធានី/ខេត្ត....**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/ន.ស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខន.ស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ន.ស/រកម/..../... ចុះថ្ងៃទី... ខែ.... ឆ្នាំ... ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួង.....
- បានឃើញព្រះរាជក្រមលេខ ន.ស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ....ចុះថ្ងៃទី...ខែ....ឆ្នាំ.....ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ..........
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ......អនក្រ.បក ចុះថ្ងៃទី....ខែ....ឆ្នាំ..... ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួង/ស្ថាប័ន/អង្គភាព
- បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ញាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញប្រកាសលេខ ០០៤ សហវ.ចុះថ្ងៃទី ១៥ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការអនុវត្តបទបញ្ញាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញប្រកាសលេខ ១៨៩ សហវ.ប្រ.ក ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១៣ ស្តីពីការដាក់ឱ្យអនុវត្តចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិការបស់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញប្រកាសលេខ ២១១ សហវ.ប្រ.ក ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ២០១៣ ស្តីពីការដាក់ឱ្យអនុវត្តមាតិកាគណនីនៃប្លង់គណនេយ្យថវិការបស់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ

-បានឃើញប្រកាសលេខ ១៨៩០ សហវ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥ ស្តីពីនីតិវិធីនៃការគ្រប់គ្រងរជ្ជទេយ្យចំណូលសម្រាប់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ

-យោងតាមតម្រូវការចាំបាច់នៃការងារសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបច្ចុប្បន្ន

**សម្រេច**

**ប្រការ១.-**

ត្រូវបានបង្កើតរជ្ជទេយ្យចំណូលនៅ ........ដើម្បីធ្វើការប្រមូលចំណូលមិនមែនសារពើពន្ធផ្សេងៗ អនុលោមតាមបទប្បញ្ញត្តិជាធរមាន។ បញ្ជីរាយប្រភេទចំណូលដែលរជ្ជទេយ្យករត្រូវបានអនុញ្ញាតឱ្យប្រមូល មានដូចខាងក្រោម÷

១. គណនី/អនុគណនី............ អត្ថន័យ....................... ចំនួនទឹកប្រាក់.......................................................

២. គណនី/អនុគណនី............ អត្ថន័យ....................... ចំនួនទឹកប្រាក់.......................................................

៣.........................................................................................................................................................

សរុបទឹកប្រាក់:..................................................

**ប្រការ២.-**

ចំនួនទឹកប្រាក់អតិបរមា ដែលអនុញ្ញាតទុកនៅក្នុងបេឡាមានកំណត់ត្រឹមចំនួន..................... (សរសេរជាអក្សរ)។

**ប្រការ៣.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៤.-**

ប្រធានរតនាគាររាជធានី/ខេត្ត... ប្រធានមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី/ខេត្ត.... ប្រធានមន្ទីរ..... ឬប្រធានអង្គភាពថវិកា...រាជធានី/ខេត្ត........ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានី/ខេត្ត............ ថ្ងៃទី...... ខែ...... ឆ្នាំ......

**ប្រធានមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី/ខេត្ត......** **ប្រធានមន្ទីរ.... ឬ ប្រធានអង្គភាពថវិកា.... រាជធានី/ខេត្ត....**

**<u>កន្លែងទទួល÷</u>**

- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ក្រសួង.....(ជូនជ្រាប)
- ដូចប្រការ៤ (ដើម្បីមុខការ)
- ឯកសារ-កាលប្បវត្តិ

**ឧបសម្ព័ន្ធទី១.២**

គំរូលិខិតស្នើសុំបង្កើតរជ្ជទេយ្យចំណូលនៅមន្ទីរជំនាញរាជធានី ខេត្ត ឬ អង្គភាពថវិកានៅថ្នាក់រាជធានី ខេត្ត
ដែលបានអនុវត្តរជ្ជទេយ្យចំណូល

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួង.....**
**មន្ទីរ.......**

**ប្រធានមន្ទីរ......ឬ ប្រធានអង្គភាពថវិកា......រាជធានី/ខេត្ត.......**

**សូមគោរពជូនលោក/លោកស្រីប្រធានមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី/ខេត្ត.......**

**តាមរយៈ** លោក/លោកស្រីប្រធានរតនាគាររាជធានី/ខេត្ត......

**កម្មវត្ថុ** សំណើសុំបង្កើតរជ្ជទេយ្យចំណូលនៅមន្ទីរ.....ឬ អង្គភាពថវិកា.......រាជធានី/ខេត្ត........

**យោង** -អនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ញាទូទៅនៃគណនេយ្យសាធារណៈ

-បានឃើញប្រកាសលេខ ១៨៩០ សហវ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥ ស្តីពីនីតិវិធីនៃការគ្រប់គ្រងរជ្ជទេយ្យចំណូលសម្រាប់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ

-សៀវភៅថវិកានៃច្បាប់ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ.......

សេចក្តីដូចមានចែងក្នុងកម្មវត្ថុខាងលើ ខ្ញុំសូមគោរពជម្រាបជូនលោក/លោកស្រីប្រធាន មេត្តាជ្រាបថា៖ ដោយមានការចាំបាច់សម្រាប់ការប្រមូលចំណូលចូលថវិការដ្ឋឱ្យបានទាន់ពេលវេលា និងមានប្រសិទ្ធិភាពខ្ពស់នៅរាជធានី/ខេត្ត.....ស្នើសុំបង្កើតរជ្ជទេយ្យចំណូលសម្រាប់ឆ្នាំ.........កំណត់ប្រភេទចំណូលមិនមែនសារពើពន្ធដូចខាងក្រោម៖

១.គណនី/អនុគណនី...................អត្ថន័យ.......................ចំនួនទឹកប្រាក់...........................................

២.គណនី/អនុគណនី................. អត្ថន័យ.......................ចំនួនទឹកប្រាក់...........................................

៣.........................................................................................................................................

សរុបទឹកប្រាក់:.....................................

អាស្រ័យហេតុដូចបានជម្រាបជូនខាងលើសូមលោក/លោកស្រីប្រធានមេត្តាពិនិត្យនិងសម្រេចឱ្យមន្ទីរ.....ឬអង្គភាពថវិកា......បង្កើតរជ្ជទេយ្យចំណូលដូចបានស្នើខាងលើ ដោយក្តីអនុគ្រោះ។

ធ្វើនៅរាជធានី/ខេត្ត............ ថ្ងៃទី......ខែ......ឆ្នាំ......

**ប្រធានមន្ទីរ....... ឬ ប្រធានអង្គភាពថវិកា.... រាជធានី/ខេត្ត......**

លេខ...................

បានឃើញ និង.........................

ថ្ងៃទី........ខែ........ឆ្នាំ................

**ប្រធានរតនាគាររាជធានី/ខេត្ត......**

**ឧបសម្ព័ន្ធទី២.១**

គំរូសេចក្តីសម្រេចស្តីពីការតែងតាំងរដ្ឋទេយ្យករចំណូលនៅមន្ទីរជំនាញរាជធានី ខេត្ត ឬអង្គភាពថវិកានៅថ្នាក់រាជធានី ខេត្ត ដែលបានអនុវត្តរដ្ឋទេយ្យចំណូល

**សេចក្តីសម្រេច**

**ស្តីពី**

**ការតែងតាំងរដ្ឋទេយ្យករចំណូល**

**នៅមន្ទីរ......... ឬ អង្គភាពថវិកា...........រាជធានី/ខេត្ត...........**

**ប្រធានមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី/ខេត្ត.......**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/ន.ស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខន.ស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ន.ស/រកម/..../.... ចុះថ្ងៃទី... ខែ....ឆ្នាំ....ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួង......
- បានឃើញព្រះរាជក្រមលេខ ន.ស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ.... ចុះថ្ងៃទី... ខែ.... ឆ្នាំ..... ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ..........
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ......អនក្រ.បក ចុះថ្ងៃទី.... ខែ.....ឆ្នាំ..... ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួង/ ស្ថាប័ន/អង្គភាព
- បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញប្រកាសលេខ ០០៤ សហវ.ចុះថ្ងៃទី ១៥ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការអនុវត្តបទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញប្រកាសលេខ ១៨៩ សហវ.ប្រ.ក ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១៣ ស្តីពីការដាក់ឱ្យអនុវត្តចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិការបស់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ

- បានឃើញប្រកាសលេខ ២១១ សហវ.ប្រ.ក ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ២០១៣ ស្តីពីការដាក់ឱ្យអនុវត្តមាតិកាគណនីនៃប្លង់គណនេយ្យថវិការបស់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញប្រកាសលេខ ១៨៩០ សហវ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥ ស្តីពីនីតិវិធីនៃការគ្រប់គ្រងរជ្ជទេយ្យចំណូលសម្រាប់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ
- យោងតាមតម្រូវការចាំបាច់នៃការងារសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបច្ចុប្បន្ន

## សម្រេច

**ប្រការ១.–**

ត្រូវបានតែងតាំងមន្ត្រីរាជការ នៃមន្ទីរ.......ឬអង្គភាពថវិកា.....រាជធានី/ខេត្ត.................ដូចខាងក្រោម÷

១.លោក/លោកស្រី............(ឈ្មោះ).............មុខងារ..........ជារជ្ជទេយ្យករចំណូលនៅមន្ទីរ......ឬអង្គភាពថវិកា......

២.លោក/លោកស្រី..........(ឈ្មោះ)...........មុខងារ..........ជារជ្ជទេយ្យករចំណូលរងនៅមន្ទីរ......ឬអង្គភាពថវិកា......

(តែងតាំងតាមការចាំបាច់)

**ប្រការ២.–**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៣.–**

ប្រធានរតនាគាររាជធានី/ខេត្ត....ប្រធានមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី/ខេត្ត....ប្រធានមន្ទីរ....ឬអង្គភាពថវិកា.....រាជធានី/ខេត្ត....ព្រមទាំងសាមីខ្លួន ដូចមានចែងក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានី/ខេត្ត............ ថ្ងៃទី......ខែ......ឆ្នាំ......

**ប្រធានមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី/ខេត្ត.....**

**<u>កន្លែងទទួល÷</u>**

- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ក្រសួង.....(ជូនជ្រាប)
- ដូចប្រការ៣ (ដើម្បីមុខការ)
- ឯកសារ-កាលប្បវត្តិ

**ឧបសម្ព័ន្ធទី២.២**

គំរូលិខិតស្នើសុំតែងតាំងរជ្ជទេយ្យករចំណូលនៅមន្ទីជំនាញរាជធានី ខេត្ត ឬអង្គភាពថវិកាថ្នាក់រាជធានី ខេត្ត
ដែលបានអនុវត្តរជ្ជទេយ្យចំណូល

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួង.....**

**មន្ទីរ.......**

**ប្រធានមន្ទីរ........រាជធានី/ខេត្ត.........**

**សូមគោរពជូនលោក/លោកស្រីប្រធានមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី/ខេត្ត.......**

**តាមរយៈ**: លោក/លោកស្រីប្រធានរតនាគាររាជធានី/ខេត្ត......

**កម្មវត្ថុ** សំណើសុំតែងតាំងរជ្ជទេយ្យករចំណូលនៅមន្ទីរ......ឬអង្គភាពថវិកា.....រាជធានី/ខេត្ត........

**យោង** -អនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្ដីពីបទបញ្ញត្តិទូទៅនៃគណនេយ្យសាធារណៈ

-បានឃើញប្រកាសលេខ ១៨៩០ សហវ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥ ស្ដីពីនីតិវិធីនៃការគ្រប់គ្រងរជ្ជទេយ្យចំណូល សម្រាប់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ

-តម្រូវការចាំបាច់របស់មន្ទីរ......ឬអង្គភាពថវិកា......រាជធានី/ខេត្ត......

សេចក្ដីដូចមានចែងក្នុងកម្មវត្ថុខាងលើ ខ្ញុំសូមគោរពជម្រាបជូនលោក/លោកស្រីប្រធាន មេត្តាជ្រាបថា÷ ដើម្បីឱ្យការគ្រប់គ្រងហិរញ្ញវត្ថុរបស់មន្ទីរ...ឬអង្គភាពថវិកា...រាជធានី/ខេត្ត...បានល្អប្រសើរ ស្របតាមបទបញ្ញត្តិទូទៅនៃគណនេយ្យសាធារណៈ មន្ទីររាជធានី...ឬអង្គភាពថវិកា...រាជធានី/ខេត្ត.....ស្នើសុំតែងតាំងរជ្ជទេយ្យករចំណូល ដែលមានរាយនាមដូចខាងក្រោម÷

១.លោក/លោកស្រី............(ឈ្មោះ)............មុខងារ..........ជារជ្ជទេយ្យករចំណូលនៅមន្ទីរ......ឬអង្គភាពថវិកា......

២.លោក/លោកស្រី..........(ឈ្មោះ)...........មុខងារ..........ជារជ្ជទេយ្យករចំណូលរងនៅមន្ទីរ......ឬអង្គភាពថវិកា......

(តែងតាំងតាមការចាំបាច់)

អាស្រ័យហេតុដូចបានជម្រាបជូនខាងលើ សូមលោក/លោកស្រីប្រធានមេត្តាពិនិត្យនិងសម្រេចតែងតាំងមន្ត្រីដូចបានស្នើខាងលើដោយក្ដីអនុគ្រោះ។

ធ្វើនៅរាជធានី/ខេត្ត.....ថ្ងៃទី.....ខែ......ឆ្នាំ........

**ប្រធានមន្ទីរ....ឬប្រធានអង្គភាពថវិកា....រាជធានី/ខេត្ត.......**

លេខ...................

បានឃើញ និង.........................

ថ្ងៃទី........ខែ........ឆ្នាំ................

**ប្រធានរតនាគាររាជធានី/ខេត្ត......**